# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date):13-Jul-2012, 13:41
CMS/CFO: Sann Rada

**អាង ឧត្តម និង Michael G. KARNAVAS**
សហមេធាវីការពារក្តី លោក អៀង សារី
ថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០១២

ផ្ញើជូន: **Susan LAMB**
មន្ត្រីច្បាប់ជាន់ខ្ពស់, អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក

ចម្លងជូន: **ក្រុមមេធាវីការពារក្តី**

**ការិយាល័យសហព្រះរាជអាជ្ញា**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

យោង: ការជំទាស់ទៅនឹងចម្លើយសាក្សី

ជូនចំពោះលោកស្រី Lamb,

យើងផ្ញើជូនអនុស្សរណៈនេះដើម្បីស្នើសុំការបញ្ជាក់ **ក.**ថាតើអង្គជំនុំជម្រះសាលាដំបូងនឹងស្តាប់ការជំទាស់ទៅនឹងចម្លើយសាក្សី ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា នៅពេលពេលណា និងដោយរបៀបណា និង **ខ.**ថាតើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី ២ នៃការជម្លៀសប្រជាជន និងបញ្ហាភ័ស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធសាធារណៈ IV ("សំណើទី២")[1] មានភាពចាំបាច់ដែរ ឬយ៉ាងណា។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យទទួលយកចម្លើយសាក្សីនានាដែលទាក់ទងនឹងដំណាក់កាលទី ២ នៃការជម្លៀសប្រជាជន និងបញ្ហាភ័ស្តុតាងផ្សេងទៀត ជាមួយឧបសម្ព័ន្ធសម្ងាត់ I, II, III និងឧបសម្ព័ន្ធសាធារណៈ IV, ថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២, E208/2។

Original EN: 00823491-00823494

កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១២ សហព្រះរាជអាជ្ញា បានដាក់សំណើស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីលំនៅប្រជាជននៅដំណាក់កាលទី១ (“សំណើទី១”)[2]។ ក្រោយពេលនោះបន្តិច នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានា នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[3]។ អង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា ក្រុមមេធាវីការពារក្តី “ត្រូវបាន”ផ្តល់សិទ្ធិឲ្យធ្វើការជំទាស់ទៅនឹងចម្លើយសាក្សីដែលបានផ្តល់ស្តាប់ក.ស.ច.ស ដែលបានស្នើឲ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុងករណីសាក្សីផ្តល់ចម្លើយនោះមិនមានវត្តមានមកផ្តល់សក្ខីកម្ម និងថ្លែងថា “កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះអាចមានតម្លៃជាភ័ស្តុតាង ឬមានទម្ងន់ជាភ័ស្តុតាងតិចតួចប៉ុណ្ណោះ ប្រសិនបើមាន ដោយសារកង្វះឱកាសដើម្បីតទល់គ្នា ឬដោយសារមានចំណុចខ្វះខាតជាសារវន្តនានានៅក្នុងកំណត់ហេតុ ឬប្រតិចារឹកទាំងអស់នេះត្រូវបានលើកឡើងពាក់ព័ន្ធនឹងភាពត្រឹមត្រូវ ឬភាពគួរឲ្យជឿជាក់បាន”[4]។

អង្គជំនុំជម្រះសលាដំបូង បានបង្គាប់ឲ្យភាគីទាំងអស់ដែលមានបំណងដាក់ចម្លើយសាក្សី នៅចំពោះមុខអង្គជំនុំជម្រះ **ក.**ពិនិត្យឡើងវិញនូវរាល់ឯកសារទាំងអស់ ដែលមាននៅលើបញ្ជីរបស់ខ្លួន ដើម្បីឲ្យស្របជាមួយលក្ខណៈវិនិច្ឆ័យស្តីពីភាពអាចទទួលយកបានដែលបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង **ខ.**បញ្ជាក់គោលបំណងនៃភ័ស្តុតាងនីមួយៗឲ្យបានច្បាស់លាស់ ឬប្រភេទនៃភ័ស្តុតាងនីមួយៗ **គ.**ពិចារណាស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងតែភ័ស្តុតាងមួយសម្រាប់ជាគំរូ ដែលតំណាងឲ្យប្រភេទនៃភ័ស្តុតាងនីមួយៗ និង **ឃ.**ផ្តល់ការបញ្ជាក់ខាងលើ ត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបុងអាចកំណត់ពេលសវនាការ ឬក៏អនុញ្ញាតឲ្យដាក់ការជំទាស់បានឆាប់រហ័ស[5]។ អង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ខ្លួន “នឹងកំណត់ពេលសវនាការនាពេលវេលាសមស្រប ឬក៏ផ្តល់ឱកាសឲ្យភាគីដាក់

---

[2] សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីលំនៅប្រជាជន នៅដំណាក់កាលទី១ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០១២, E208។

[3] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ E96/7។

[4] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៧។

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៥។

ការជំទាស់ ដែលពាក់ព័ន្ធទៅនឹងភ័ស្តុតាងដែលបានស្នើឡើង អនុលោមតាមវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង[6]"។

កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តី បានដាក់ការឆ្លើយតបទៅនឹងសំណើទី១។ ក្រុមមេធាវីការពារក្តី មានបំណងជំទាស់ទៅនឹងចម្លើយសាក្សីជាច្រើន ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ ក្រុមមេធាវីការពារក្តី នឹងធ្វើការជំទាស់នឹងចម្លើយសាក្សី នៅពេលដែលសហព្រះរាជអាជ្ញា បានរៀបចំដាក់ អនុលោមតាមសេចក្តីណែនាំដែលមានចែងក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ និងនៅពេលដែលអង្គជំនុំជម្រះសាលាដំបូង បានកំណត់ពេលឲ្យដាក់ការជំទាស់។

កាលពីថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ២០១២ ក្រុមមេធាវីការពារក្តីទទួលបានការជូនដំណឹងអំពីសំណើទីពីរ។ ក្នុងសំណើនេះ សហព្រះរាជអាជ្ញាបានស្នើឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹង "ការផ្លាស់ប្តូរទីលំនៅប្រជាជនទៅដំណាក់កាលទី២" និងស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាសំណើទីមួយ ទោះបីជាសំណើនោះត្រូវបានដាក់ មុនពេលអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីណែនាំក្នុងសេចក្តីសម្រេចរបស់ខ្លួននៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ក៏ដោយ។ សហព្រះរាជអាជ្ញា ក៏បានជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងថា ខ្លួនរំពឹងថានឹងដាក់សំណើទីបីសុំឲ្យទទួលយកចម្លើយសាក្សី មុនពេលកំណត់ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២[7]។

សូមជូនដំណឹងដល់ពួកយើង ថាតើអង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យមានការឆ្លើយតបទៅនឹងសំណើទីពីរ (ឬសំណើបែបនេះដទៃទៀតនៅពេលខាងមុខ) ដែរ ឬយ៉ាងណា បើសិនយើងមានបំណងដាក់ការជំទាស់ទៅនឹងចម្លើយសាក្សី ដែលស្នើដោយសហព្រះរាជអាជ្ញា។

លើសពីនេះទៅទៀត សូមជម្រាបជូនអង្គជំនុំជម្រះសាលាដំបូងអំពីតម្រូវការ/សំណើសុំរបស់យើងនូវពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការជំទាស់ទៅនឹងចម្លើយសាក្សីដែលបានស្នើឡើង។ យើងបានពិនិត្យមើលខ្សែ

---

[6] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៦។

[7] សំណើទីពីរ កថាខណ្ឌ ៧។

អាត់សំឡេង (ដែលមាន) ស្ដីពីចម្លើយសាក្សីរបស់ក.ស.ច.ស ចំនួន ១៨៦[8] ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាក្នុងសំណើទីមួយរបស់ខ្លួន។ យើងនឹងអនុវត្តដំណើរការនេះឡើងវិញជាមួយនឹងចម្លើយសាក្សីរបស់ក.ស.ច.ស ចំនួន ៥៨[9] ដែលបានស្នើឡើងក្នុងសំណើទីពីរ និងចម្លើយសាក្សីបន្ថែមទៀត ដែលបានស្នើឡើង មុនពេលកំណត់ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។ ខ្សែអាត់សំឡេងនីមួយៗ មានរយៈពេលយ៉ាងហោចណាស់កន្លះថ្ងៃ ហើយជាទូទៅមិនមានប្រតិចារឹកនៃខ្សែអាត់សំឡេងទាំងនោះឡើយ។ នេះជាការងារដែលត្រូវចំណាយពេលច្រើន ប៉ុន្តែយើងយល់ឃើញថា វាមានភាពចាំបាច់ក្នុងការអនុវត្តកាតព្វកិច្ចប្រកបដោយការយកចិត្តទុកដាក់ត្រឹមត្រូវ។

ក្នុងអំឡុងពេលដែលយើងពិនិត្យឡើងវិញទៅលើចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស ទាំងនេះ យើងបានឃើញថា ចម្លើយមួយចំនួនមានកំហុសឆ្គង។ ចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស មួយចំនួនមានខ្លឹមសារខុសគ្នាជាសត្យានុម័តពីកំណត់ហេតុជាខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយសាក្សីទាំងនេះ (ជាបញ្ហាដែលធ្លាប់បានលើកឡើងដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងចាប់អារម្មណ៍រួចមកហើយ)[10] ហើយចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស ដទៃទៀតមិនមានភាពពេញលេញ ឬនាំឲ្យមានការយល់ខុស។ ជាធម្មតា ចំណុចនេះនឹងនាំឲ្យមានការចោទសួរពីភាពជឿជាក់បាននៃចម្លើយសាក្សីទាំងនេះ។

---

[8] សូមកត់សម្គាល់ថា សំណើទីមួយបង្ហាញថា ចម្លើយសាក្សី ក.ស.ច.ស ចំនួន ១៨៦ ត្រូវបានស្នើឡើង។ កថាខណ្ឌ ១១ បង្ហាញថា មានចម្លើយសាក្សីចំនួន ១២២ នៅក្នុងឧបសម្ព័ន្ធ ១ និងកថាខណ្ឌ ១៧ បង្ហាញថាឧបសម្ព័ន្ធ ២ មានចម្លើយសាក្សីចំនួន ៦៤។ ក្នុងសំណើនោះ ក៏បង្ហាញនូវចម្លើយសាក្សីចំនួនពីរ នៅក្នុងឧបសម្ព័ន្ធ ក.ស.ព ដែលមិនមែនជាចម្លើយសាក្សីរបស់ ក.ស.ច.ស ប៉ុន្តែជាការដកស្រង់ចេញពីសៀវភៅទៅវិញ។ *សូមមើល* សំណើទីមួយ ឧបសម្ព័ន្ធទី ៤, # ២, ១២៨។

[9] សូមកត់សម្គាល់ថា កថាខណ្ឌ៩ នៃសំណើទីពីរ បង្ហាញថាចម្លើយសាក្សីចំនួន ៥៨ ត្រូវបានស្នើឡើង ប៉ុន្តែឧបសម្ព័ន្ធ រាយបញ្ជីតែចម្លើយសាក្សីចំនួន ៥៧ ប៉ុណ្ណោះ។ យើងឃើញថា ចម្លើយសាក្សីចំនួន៨ មិនមែនជាចម្លើយសាក្សីរបស់ក.ស.ច.ស ឡើយ ទោះជាកថាខណ្ឌ៥ នៃសំណើទីពី បានលើកឡើងថា ចម្លើយសាក្សីនោះជាចម្លើយសាក្សីរបស់ក.ស.ច.ស ក៏ដោយ។ សូមកត់សម្គាល់ផងដែរថា ចម្លើយសាក្សីមួយចំនួន ជាចម្លើយសាក្សីដូចគ្នា ដែលបានស្នើក្នុងសំណើទីមួយ។ យើងឃើញថា មានចម្លើយសាក្សីដូចគ្នាចំនួន ២៧។

[10] ចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស មួយចំនួនមានខ្លឹមសារខុសពីកំណត់ហេតុជាខ្សែអាត់សំឡេងនៃការស្ដាប់ចម្លើយសាក្សីទាំងនេះជាបញ្ហាមួយដែលធ្លាប់បានលើកឡើងរួចមកហើយដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងចាប់អារម្មណ៍។ *សូមមើល ឧទាហរណ៍* សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្ដាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E142។

ចំណុចដែលគួរឲ្យខ្វល់ខ្វាយជាងគេគឺ ភាពមិនស៊ីសង្វាក់គ្នាដែលបានកើតឡើងក្នុងពេលស្តាប់ចម្លើយ។ យើងខ្ញុំបានកត់សម្គាល់ឃើញថា ការស្តាប់ចម្លើយមួយចំនួនពុំមានអាត់សំឡេងទេ[11] ឬថា មានការបញ្ជាក់ច្បាស់តាមរយៈខ្សែអាត់សំឡេងនោះគឺថា មានការស្តាប់ចម្លើយជាមុនត្រូវបានធ្វើឡើងជាមួយសាក្សីដោយមិនមានថតសំឡេង[12]។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងនឹងរម្លឹកឡើងវិញគឺថា ក្នុងពេលសវនាការនាពេលថ្មីៗនេះ លោក អឿន តាន បានផ្តល់សក្ខីកម្មថា អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសាកសួរគាត់នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ ហើយថា ការស្តាប់ចម្លើយនេះត្រូវបានថតសំឡេងពីមុនរួចមកហើយ[13]។ បន្ទាប់មកលោក អឿន តាន បានលាតត្រដាងថា មួយថ្ងៃមុនការស្តាប់ចម្លើយនេះ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសាកសួរគាត់ពេញមួយថ្ងៃ ដោយគ្មានថតសំឡេងចំពោះការសួរសំណួរ ឬចម្លើយរបស់គាត់ទេ[14]។ ចម្លើយសាក្សីដែលបានស្តាប់ដោយ ក.ស.ច.ស នៅថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ មិនបាននិយាយដល់ការស្តាប់ចម្លើយពីមុនទេ។ ដោយបានដឹងពីការសង្ស័យចំពោះ "អ្វីដែលមានក្នុងខ្សែអាត់សំឡេង និងអ្វីដែលបានកើតមានក្នុងពេលស្តាប់ចម្លើយ" រវាងអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស និងលោក អឿន តាន នោះហើយ[15] ទើបសហព្រះរាជអាជ្ញាស្នើសុំប្រតិចារឹកនៃការស្តាប់ចម្លើយ កាលពីថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៨ និងការបញ្ជាក់ពី ក.ស.ច.ស ថាតើ មានកំណត់ហេតុនៃការស្តាប់ចម្លើយ កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០០៨ ឬយ៉ាងណា[16]។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងមិនបានចេញសេចក្តីសម្រេចដោយផ្ទាល់មាត់ចំពោះសំណើនេះក៏ដោយ អង្គជំនុំជម្រះបានលើកឡើងថា ភាគីអាចដាក់បញ្ហានេះទៅក្នុងសេចក្តីសន្និដ្ឋានរបស់ខ្លួនបាន[17]។

វាជាការសមរម្យក្នុងការរម្លឹកឡើងវិញថា សហព្រះរាជអាជ្ញាអន្តរជាតិលោក Andrew Cayley បានទទួលស្គាល់ថា ការស្តាប់ចម្លើយដើមដែលបានធ្វើឡើងសម្រាប់សំណុំរឿង ០០៣ និង ០០៤ ក៏មានលេចចេញនូវ

---

[11] ជាឧទាហរណ៍ ឯកសារ D199/15។ មានលេចឡើងថា យ៉ាងហោចណាស់ចម្លើយសាក្សីចំនួន ១២ ដែលត្រូវបានស្នើសុំនៅក្នុងសំណើលើកទីមួយនោះ ពុំមានកំណត់ហេតុជាខ្សែអាត់សំឡេងនៅក្នុងសំណុំរឿងទេ។

[12] ជាឧទាហរណ៍ ឯកសារ D125/92R នៅត្រង់ 00:07:58-00:08:10។

[13] ប្រតិចារឹកនៃសវនាការ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E1/87.1 ទំព័រ 47។

[14] *ដូចខាងលើ* ទំព័រ 47-48។

[15] *ដូចខាងលើ* ទំព័រ 53។

[16] *ដូចខាងលើ*។

[17] *ដូចខាងលើ* ទំព័រ 54។

កំហុសឆ្គងស្រដៀងគ្នានេះដែរ មានន័យថា ក្នុងការប្រៀបធៀបរវាងកំណត់ហេតុជាខ្សែអាត់សំឡេងទៅនឹងចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស មានលេចចេញនូវ “ភាពមិនស្របគ្នា ឬចន្លោះប្រហោងមួយចំនួន”[18]។ ការពិត លំនាំបែបនេះគឺជាបញ្ហា ជាពិសេស នៅពេលពិចារណាទៅដល់ទំនោររបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការទទួលយកសេចក្ដីសង្ខេបចម្លើយសាក្សីដែលបានស្ដាប់ដោយ ក.ស.ច.ស ថាមានភាពសុក្រឹត្យ និងពេញលេញ ដោយមានហត្ថលេខា ឬស្នាមមេដៃនោះ[19]។

សរុបមក ដោយពិចារណាថា សហព្រះរាជអាជ្ញាបានស្នើសុំ (និងបន្តស្នើសុំ) ឱ្យទទួលយកចម្លើយសាក្សីរាប់រយទៀតនោះ និងថា អង្គជំនុំជម្រះសាលាដំបូងបានតម្រូវឱ្យភាគីបង្ហាញពីភាពមិនស្របគ្នាដែលមានលក្ខណៈពិសេស (ដែលនឹងតម្រូវថា ភាគីត្រូវពិនិត្យឡើងវិញនូវកំណត់ហេតុជាខ្សែអាត់សំឡេង ដល់ទៅចំនួនរាប់រយម៉ោង បើមិនដល់រាប់ពាន់ម៉ោងក៏ដោយ)[20] យើងខ្ញុំសូមលើកឡើងដោយគោរពថា អង្គជំនុំជម្រះសាលាដំបូងត្រូវផ្ដល់ពេលវេលាឱ្យបានគ្រប់គ្រាន់ដល់ភាគី ដើម្បីរៀបចំការជំទាស់ទៅនឹងចម្លើយសាក្សីដែលបានស្នើសុំ។ ចំណុចនេះស្របគ្នាទាំងស្រុងទៅនឹងអ្វីដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានទទួលស្គាល់រួចមកហើយ មានន័យថា “អង្គជំនុំជម្រះនឹងពិចារណាអំពីការចោទប្រកាន់អំពីចំណុចមិនស៊ីសង្វាក់រវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្ដាប់ចម្លើយ នៅពេលមានការចង្អុលបង្ហាញច្បាស់លាស់គ្រប់គ្រាន់អំពីចំណុចមិនស៊ីសង្វាក់នេះ” ហើយថា “ភាគីណាដែលលើកការជំទាស់ ... ត្រូវមានបន្ទុកបង្ហាញឱ្យបានច្បាស់លាស់ នូវចំណុចមិនស៊ីសង្វាក់ដែលត្រូវបានចោទប្រកាន់

---

[18] ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកំណត់ហេតុស្ដាប់ចម្លើយសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ និង ០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E127 កថាខណ្ឌ ១៤។

[19] គេគួររម្លឹកដល់សំណួរដែលលោកចៅក្រម Lavergne បានសួរសាក្សី ឡុង នរិន្ទ និង បានសាកសួរយោបល់សហមេធាវីការពារក្ដីលោក អៀង សារី គឺលោក Michael G. Karnavas ពាក់ព័ន្ធនឹងការទទួលយកចម្លើយសង្ខេប។ លោក Karnavas បានពន្យល់ថា “អ្វីដែលយើងខ្ញុំព្រួយបារម្ភនោះគឺ ការពិតគឺថា អ្នកស៊ើបអង្កេតបានផ្ដល់ចម្លើយ និងបំភ្លៃសាក្សី ហើយបន្ទាប់មកពួកគេក៏រៀបចំដោយសង្ខេប ហើយបន្ទាប់យើងក៏មកកាន់ទីនេះ ហើយនៅពេលនេះយើងនឹងធ្វើពុតថា អត្ថបទសង្ខេបនេះជាការឆ្លុះបញ្ចាំងដោយសុក្រឹត្យ។ នោះហើយជាបញ្ហា”។ ប្រតិចារឹកសវនាការ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១១ ឯកសារ E1/23.1 ទំព័រ 21-26 (ដកស្រង់ចេញពីទំព័រ 25-26)។

[20] សំណើសុំលើកទីពីរ កថាខណ្ឌ ៧។

និងជូនដំណឹងឲ្យបានទាន់ពេលវេលាមកអង្គជំនុំជម្រះ និងភាគីដទៃទៀតអំពីការចោទប្រកាន់អស់ទាំងនេះ និងឯកសារពាក់ព័ន្ធ”[21]។

សូមលោកស្រីមេត្តាទទួលយកសំណើ ដោយក្តីគោរពរាប់អាន។

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីការពារក្តីលោក អៀង សារី

[21] សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ស.ច.ស ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ឯកសារ E142/3 កថាខណ្ឌ ១២។

Original EN: 00823491-00823494